ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៧៧ "ក្រ.ជ"

ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៩១

ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨

-សំណុំរឿងស៊ើបសួរលេខ ២០៩៦

ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨

-សំណុំរឿងជំនុំជម្រះលេខ ៣៤៤៨

ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ០២ និង ៣០ នាទីរសៀល នៅសាលសវនាការទី៤ ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៩១ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] រ៉ូហ្សាលី ភេទប្រុស អាយុ ១៧ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរឥស្លាម សាសនាឥស្លាម ទីកន្លែងកំណើតនៅ[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រ៉ូសេត "រស់" ម្ដាយឈ្មោះ [redacted] សារីហ្វាស់ "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។

ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ឃាត់ខ្លួននៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៨៥១ "ជ" ដ.ឃ.ង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុនៃរឿងមានដូចតទៅ

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ កម្លាំងអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ សហការជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាលឫស្សីកែវ បានចុះបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានជនសង្ស័យឈ្មោះ [redacted] រ៉ូហ្សាលី ភេទប្រុស រួមទាំងវត្ថុតាងគ្រឿងញៀនចំនួន ១០កញ្ចប់តូច។ ជនសង្ស័យឈ្មោះ [redacted] រ៉ូហ្សាលី បានឆ្លើយសារភាពថា ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ ហ្សាក់ ភេទប្រុស អាយុប្រហែល៣០ឆ្នាំ ដើម្បីយកមកលក់បន្ត។

-បានឃើញ របាយការណ៍សំយោគលេខ ០៤៥/១៨ រ.ប.ក ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ របស់អធិការដ្ឋាននគរបាលខណ្ឌឬស្សីកែវ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២១២៩ អ.យ.ព ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ស្នើសុំបើកការស៊ើបសួរលើអង្គហេតុលើជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្វាលី ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៤១ អ.យ.ព ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលស្នើសុំបញ្ជូនជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្វាលី ទៅជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦១០ "ជ" ដ.ង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្វាលី ទៅជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្វាលី បានឆ្លើយថា៖ ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ២៣ និង ៣០នាទី ដោយសារតែសមត្ថកិច្ចរកឃើញគ្រឿងញៀននៅលើខ្លួន។ គ្រឿងញៀនដែលសមត្ថកិច្ចរកឃើញនេះខ្លួនទិញមក ០១កញ្ចប់ តម្លៃ ១០.០០០ រៀល ពេលលក់វិញ ០១កញ្ចប់តម្លៃ ១៥.០០០ រៀល។ ក្នុង ០១ថ្ងៃ ខ្លួនលក់គ្រឿងញៀនបានពី ០៥ កញ្ចប់ ទៅ ១០ កញ្ចប់ ខ្លួនចេះជក់គ្រឿងញៀន និងលក់គ្រឿងញៀនអស់រយៈពេលប្រហែល ១ខែ ហើយ។ គ្រឿងញៀននោះខ្លួនបានទិញពីឈ្មោះ ហ្សាក់។

-ប្រធានក្រុមប្រឹក្សាឱ្យក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៥៥៣៦/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ការសួរដេញដោលក្នុងពេលសវនាការ និងពិនិត្យភស្តុតាងផ្សេងៗក្នុងសំណុំរឿងតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្វាលី តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៤១ អ.យ.ព ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដដែល និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្វាលី បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្នុងសំណុំរឿងនេះឃើញថាកូនក្តីខ្លួននៅជាអនីតិជននៅឡើយ ដែលនាំឱ្យការគិតរបស់គាត់ពុំទាន់បានវែងឆ្ងាយ ហេតុនេះខ្លួនសុំសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាផ្តល់នូវស្ថានសម្រាល់ទោសដល់កូនក្តីខ្លួន ដើម្បីឱ្យកូនក្តីខ្លួនឆាប់បានត្រឡប់ទៅជួបជុំគ្រួសារវិញ។



Scanned with CamScanner

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្សាលី បាននិយាយសំដីចុងក្រោយ៖ សុំសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្សាលី ត្រូវបានចៅក្រមស៊ើបសួរចោទប្រកាន់បញ្ជូនមកជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមរបាយការណ៍សំយោគលេខ ០៤៥/១៨ រ.ប.ក ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ របស់អធិការនគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានរាយការណ៍ថា៖ មុនពេលកើតហេតុនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ២៣ និង ៣០នាទី កម្លាំងអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ សហការណ៍ជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាលឫស្សីកែវ បានបើកកិច្ចប្រតិបត្តិការចុះបង្ក្រាបករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ក្នុងការបង្ក្រាបបទល្មើសជាក់ស្តែងកម្លាំងសមត្ថកិច្ចយើងបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ១នាក់ ឈ្មោះ [redacted] វ៉ូហ្សាលី កំពុងធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ភ្លាមៗនោះកម្លាំងសមត្ថកិច្ចយើងក៏ចុះមកធ្វើអន្តរាគមន៍ត្រួតពិនិត្យឆែកឆេរក្នុងខ្លួនជនសង្ស័យ បានរកឃើញក្រាមពណ៌សថ្លាចំនួន ១០កញ្ចប់ បន្ទាប់មកកម្លាំងសមត្ថកិច្ចយើងក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យ រួមនិងវត្ថុតាងខាងលើ នាំមកអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ដើម្បីសាកសួរនិងចាត់ការតាមច្បាប់។

៣-តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ របស់ផ្នែកនគរបាលយុត្តិធម៌ នៃអធិការនគរបាលខណ្ឌឫស្សីកែវ (ឯកសារលេខ ៥/១៤ និង ៥/១៥) បានបង្ហាញឱ្យឃើញថា វត្ថុដែលដកហូតបានពីជនជាប់ចោទរួមមាន៖ ក្រាមពណ៌សថ្លា ចំនួន ១០កញ្ចប់តូច, ថង់ប្លាស្ទិចសម្រាប់ច្រកថ្នាំញៀនមួយចំនួន និងម៉ូតូចំនួន ០១គ្រឿង ម៉ាក HONGDA C125 ពណ៌ខ្មៅ សេរីឆ្នាំ២០១៤ ពាក់ស្លាកលេខ ក្រចេះ 1D-២៧០៥។ ហើយវត្ថុទាំងនេះត្រូវបានជនជាប់ចោទទទួលស្គាល់តាមកំណត់ហេតុទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឫស្សីកែវ នៃអធិកានគរបាលខណ្ឌឫស្សីកែវ (ឯកសារលេខ ៦/១៦)។

៤-តាមកំណត់ហេតុធ្វើតេស្តិ៍បឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ (ឯកសារលេខ ៧/១៧, ៧/១៨ និង ៧/១៩) បានបង្ហាញឱ្យឃើញថា ក្រាមពណ៌សថ្លាចំនួន ១០កញ្ចប់តូច ដែលដកហូតបានពីជនជាប់ចោទ តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ (ឯកសារលេខ ៥/១៤ និង ៥/១៥) នោះ គឺមានទម្ងន់សរុប ១,១៦១ (មួយក្បៀសដប់ប្រាំមួយក្រាម) ហើយជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន។

៥-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៥៥៣៦/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, តាមកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ (ឯកសារលេខ ៧/១៧, ៧/១៨ និង ៧/១៩) និងតាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៨ របស់ផ្នែកនគរបាលយុត្តិធម៌ នៃអធិការនគរបាលខណ្ឌឫស្សីកែវ (ឯកសារលេខ ៥/១៤ និង ៥/១៥) បញ្ជាក់ឱ្យតុលាការឃើញថា ថ្នាំញៀនចំនួន ១០កញ្ចប់តូច (មានទម្ងន់សរុបចំនួន ១,១៦g) ដែលដកហូតបានពីជនជាប់ចោទ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ គឺមានវត្ថុមានបរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ គឺ ៨០,៦៣% និងមានបរិមាណភាពសុទ្ធជាសារធាតុញៀនគិតជាក្រាមសរុបចំនួន ០,៩៣៥៣០៨ ក្រាម ហើយវាជាប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រាម៉ាទឹកកក ឬអាយ) និងជាថ្នាំញៀនដែលស្ថិតនៅក្នុងតារាង II នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី បានឆ្លើយសារភាពថា៖ ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ២៣ និង ៣០នាទី ដោយសារតែសមត្ថកិច្ចរកឃើញគ្រឿងញៀននៅលើខ្លួន។ គ្រឿងញៀនដែលសមត្ថកិច្ចរកឃើញនេះខ្លួនទិញមក ០១កញ្ចប់ តម្លៃ ១០.០០០ រៀល ពេលលក់វិញ ០១កញ្ចប់តម្លៃ ១៥.០០០ រៀល។ ក្នុង ០១ថ្ងៃ ខ្លួនលក់គ្រឿងញៀនបានពី ០៥ កញ្ចប់ ទៅ ១០ កញ្ចប់ ខ្លួនចេះជក់គ្រឿងញៀន និងលក់គ្រឿងញៀនអស់រយៈពេលប្រហែល ១ខែ ហើយ។ គ្រឿងញៀននោះខ្លួនបានទិញពីឈ្មោះ ហ្សាក់។

៧-តាមចម្លើយស៊ីសង្វាក់របស់ជនជាប់ចោទដូចមានលើកឡើងនៅក្នុងចំណុចទី០៦ ខាងលើ, តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ របស់ផ្នែកនគរបាលយុត្តិធម៌ នៃអធិការនគរបាលខណ្ឌឫស្សីកែវ (ឯកសារលេខ ៥/១៤ និង ៥/១៥), តាមកំណត់ហេតុទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឫស្សីកែវ នៃអធិការនគរបាលខណ្ឌឫស្សីកែវ (ឯកសារលេខ ៦/១៦), តាមកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ (ឯកសារលេខ ៧/១៧, ៧/១៨ និង ៧/១៩) និងតាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៥៥៣៦/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺជាអង្គហេតុ និងភស្តុតាង ធ្វើឱ្យតុលាការជឿថា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ នៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពិតជាមានអង្គហេតុអំពើដែលជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី បានរក្សាទុកគ្រឿងញៀនក្រាមសង្ហា ដើម្បីទុកលក់ជាប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន (ហៅក្រាម៉ាទឹកកក ឬអាយ) ចំនួន ១០កញ្ចប់ ដែលមានទម្ងន់ ១,១៦ក្រាម ហើយមានបរិមាណភាពសុទ្ធជាសារធាតុញៀនគិតជាក្រាមសរុបចំនួន ០,៩៣៥៣០៨ ក្រាម។ អំពើរបស់ជនជាប់ចោទនេះមានធាតុផ្សំជាបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-មានធាតុផ្សំបទល្មើស និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៩-អំពើដែលជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម។

១០-ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី បានឆ្លើយសារភាពគ្រប់ដំណាក់កាល ដែលការសារភាពនេះអាចបញ្ជាក់ថា ជនជាប់ចោទបានដឹងកំហុស និងចេះទទួលខុសត្រូវនូវទង្វើរបស់ខ្លួន ណាមួយថ្នាំញៀនដែលជនជាប់ចោទយកមកធ្វើសកម្មភាព គឺមានទំហំតិចតួចប៉ុណ្ណោះ លើសពីនេះជនជាប់ចោទរូបនេះទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង។ គប្បីតុលាការលើកយកចំណុចនេះមកពិចារណាក្នុងការដាក់ទោសជនជាប់ចោទ។

១១-ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី គឺជាអនីតិជន ដែលគិតមកដល់ថ្ងៃប្រព្រឹត្តបទល្មើសជនជាប់ចោទរូបនេះទើបតែមានអាយុ ១៧ឆ្នាំ តាមវ័យរបស់ជនជាប់ចោទនេះ គឺស្ថិតនៅក្នុងស្ថានភាពមិនទាន់ ចេះពិចារណាបានខិតដល់ពីទង្វើរបស់ខ្លួនតាមផ្លូវច្បាប់នៅឡើយ លើសពីនេះជនជាប់ចោទរូបនេះមិនទាន់មានលក្ខណៈសម្បត្តិពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់នៅឡើយ។

១២-ដោយជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី គឺជាអនីតិជននៅឡើយ ដូចនេះគប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទដោយគិតទៅលើឧត្តមប្រយោជន៍របស់កុមារ និងសម្រេចដោយផ្អែកតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៣-វត្ថុតាងរួមមាន៖

ក-ស្រោមសំបុត្រពណ៌ស មានក្រាមពណ៌សថ្លាទម្ងន់ ១,១៦ (មួយក្បៀសដប់ប្រាំមួយ) ក្រាម ជារបស់ឈ្មោះ [redacted] រ៉ូហ្សាលី ជាវត្ថុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ គប្បីរឹបអូស និងបំផ្លាញចោល។ ការសម្រេចនេះយោងតាមបញ្ញត្តិមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដា សេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ក្រចេះ 1D-២៧០៥ មានលេខតួ និងលេខម៉ាស៊ីន ៩០៦២៥៦៧ (មានសោរ) លែងមានភាពចាំចាច់ដែលត្រូវរក្សាទុកតទៅទៀត គប្បីប្រគល់ឱ្យទៅម្ចាស់ដើមវិញ។

១៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីបានស្តាប់ការសួរដេញដោលក្នុងពេលសវនាការ និងពិនិត្យភស្តុតាងផ្សេងៗក្នុងសំណុំរឿង តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៤១ អ.យ.ព ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដដែល និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៥-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលីបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្នុងសំណុំរឿងនេះឃើញថា កូនក្តីខ្លួននៅជាអនីតិជននៅឡើយ ដែលនាំឱ្យការគិតគាត់របស់គាត់ពុំទាន់បានវែងឆ្ងាយ ហេតុនេះខ្លួនសុំសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាផ្តល់នូវស្ថានសម្រាល់ទោសដល់កូនក្តីខ្លួនដើម្បីឱ្យកូនក្តីខ្លួនឆាប់បានត្រឡប់ទៅជួបជុំគ្រួសារវិញ។ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៦-ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សាលី បាននិយាយសំដីចុងក្រោយថា៖ សុំសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] រ៉ូហ្សាលី ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរឥស្លាម ដាក់ទោសពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

២-វត្ថុតាងរួមមាន៖

ក-ស្រោមសំបុត្រពណ៌ស មានក្រាមពណ៌សថ្លាទម្ងន់ ១,១៦ (មួយក្បៀសដប់ប្រាំមួយ) ក្រាម ជារបស់ឈ្មោះ [redacted] វ៉ូហ្សាលី រឹបអូស និងបំផ្លាញចោល តាមបញ្ញត្តិមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៨៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដា សេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ក្រចេះ 1D-២៧០៥ មានលេខតួ និងលេខម៉ាស៊ីន ៩០៦២៥៦៧ (មានសោរ) ប្រគល់ឱ្យទៅម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្សាលី ប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩។

គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ០៧កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]